

អង្គការវ៉ឺមកកង់បី
សម្រាប់កុមារ R4C

# ពស់ស្រកាចាស់

ពស់ស្រកាចាស់៖

ជាសត្វពស់មួយប្រភេទ ដែលមានពិសជាងពស់ទូទៅ
ប៉ុន្តែវាមិនសូវចឹកពេលថ្ងៃទេ។
លើកលែងតែដើរជាន់វា ពស់នេះខ្វាក់មាន់ ងងឹតពេលថ្ងៃ
មានក្លិនសាយភាយចេញពីខ្លួនរបស់វា ដូច្នេះអ្នកដែលមាន
ច្រមុះល្អ អាចដឹងក្លិនរបស់វាបានឆាប់ផងដែរ។
ពស់នេះសំបូរនៅខេត្តបាត់ដំបង ពោធិ៍សាត់ សៀមរាប
និងខេត្តកំពង់ធំ ហើយខែរងារវានឹងចេញតាម
ជញ្ជាំងស្រូវ និងកំពកដីរដិបរដុប។



# ពស់វែកក្របី

ពស់វែកក្របី៖

ជាពស់មួយប្រភេទដែលមានពិសខ្លាំងដែរ មានសម្បុរខ្មៅ
និងបើកវែកទៅមានឆ្នូតនៅក្រោមវែករបស់វា។
ពស់នេះសំឡេងស្រែករបស់វាស្រដៀងទៅនឹងសំឡេង
មាន់ព្រៃអ៊ីចឹង អាចថាដូចគ្នាតែម្តង។
ពស់ប្រភេទនេះភាគច្រើនមាននៅក្នុងព្រៃភ្នំ។



# ពស់វែកដំបូក

ពស់វែកដំបូក៖

ជាពស់ដែលមានពិសតិចជាងពស់វែកក្របីនិង ពស់វែករនាម ដូចជាពាក្យចាស់ពោលថា ពស់វែកដំបូកមួយស្រែ ពស់វែកស្រងែមួយព្យាម ពស់វែករនាមប៉ក់ភ្លឹង។ ពស់នេះមិនសូវមានទំហំធំពេកទេ និងមិនសូវវែងពេកនោះទេ។

ពស់ប្រភេទនេះភាគច្រើនមាននៅតាមដំបូក ព្រៃជិតៗផ្ទះ ក្នុងស្រុកតែម្តង។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



# ពស់វែករនាម

ពស់វែករនាម៖

ជាសត្វដែលមានពិសសាហាវជាងគេ ពស់វែករនាម
រស់នៅក្នុងព្រៃ វាលស្រែ និងទំនាបនៃប្រទេស ឥណ្ឌា
និងតំបន់អាស៊ីអាគ្នេយ៍។

វាជាប្រភេទពស់ដ៏មានគ្រោះថ្នាក់ ហើយអាចមានប្រវែង
ដល់ ៦ម៉ែត្រ។ នៅពេលវាគិតថាមានគ្រោះថ្នាក់
វាងើបក្បាលអើតឡើងខ្ពស់ផុតពីដីរហូតដល់ ១,៥ម៉ែត្រ
រួចដំឡើងស្បែកកឱ្យរីកធំ (គេថាពស់ដកពារ)។

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C



# ពស់ក្រាយ

ពស់ក្រាយ៖

វាជាស្តេចពស់សូម្បីជញ្ជាំងប្រាសាទក៏ចរឹករូបវាដែរ

បើវាចឹកហើយវាតាមទៅរកមើលមនុស្សដែលវាបាន

ចឹកដល់ផ្ទះថាស្លាប់ហើយឬនៅ ?

សូម្បីពស់ថ្លាន់ទំងន់រយគីឡូក៏វាចឹកងាប់ដែរ។

វាមានពិសសាហាវណាស់ ប៉ុន្តែវាមិនងាយចឹកទេ

ទាល់តែយើងរំខានវាមុនបានវាចឹក ហើយពេលវាចឹកម្តងៗ

ពិសរបស់វាច្រើនជាងពស់វែកបីដងឯនោះ។



# ពស់ហនុមាន

ពស់ហនុមាន៖

ជាពស់ដែលមានសម្បុរពណ៌ខៀវ ប្រវែងវែងល្មម

វាភាគច្រើនរស់តាមដើមឈើស្លឹកឈើដែលមាន

ពណ៌បៃតង។

ពស់នេះមានពិសខ្លាំងគួរសមដែរ

វាក៏អាចបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្សដែរ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C